ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ ០០១ បទ ៣.ក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារ GMS និង មេគង្គ-ជប៉ុន

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការងារចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារ " GMS និង Mekong Japan " របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានសមាសភាព ដូចខាងក្រោម:

I-Steering Group :

| | | |
|---|---|---|
| ១-ឯកឧត្តម ខាយ ឃុនហេង | រដ្ឋលេខាធិការ ក្រសួងប.ទ. | ប្រធាន |
| ២-ឯកឧត្តម ខូវ មករា | អនុរដ្ឋលេខាធិការ ក្រសួងប.ទ. | អនុប្រធានទី១ |
| ៣-លោក គឹម វិក្រា | អគ្គនាយកទូរគមនាគមន៍កម្ពុជា | អនុប្រធានទី២ |
| ៤-លោកជំទាវ ឡេ ម៉ាយគៀង | អគ្គនាយិកាប.ទ. | សមាជិក |
| ៥-លោក គុល ញ៉ក់ | អគ្គនាយករងប.ទ. | សមាជិក |
| ៦-លោក ឡាយ វុទ្ធី | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | (Focal Point) |

II-Implementation Group:

**ក-ក្រុមការងារដឹកនាំ:**

| | | |
|---|---|---|
| ១-លោក គឹម វិក្រា | អគ្គនាយកទូរគមនាគមន៍កម្ពុជា | ប្រធាន |
| ២-លោក សន វី | អគ្គនាយករងទូរគមនាគមន៍កម្ពុជា ទទួលបន្ទុកអចិន្ត្រៃយ៍ | អនុប្រធានទី១ |
| ៣-លោក សោម សុមនោ | អគ្គនាយករងទូរគមនាគមន៍កម្ពុជា | អនុប្រធានទី២ |
| ៤-លោក អ៊ិច រិទ្ធី | ប្រធាននាយកដ្ឋានទូរគមនាគមន៍អន្តរជាតិទ.ក. | សមាជិក |

**ខ-ក្រុមការងារបច្ចេកទេស:**

| | | |
|---|---|---|
| ១-លោក ស៊ុន ចំរើន | ប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេសទ.ក. | ប្រធាន |
| ២-លោក ប៉ូ អាន | ប្រធាននាយកដ្ឋានបញ្ជូនស៊ីញ៉ាល់និងបណ្តាញកាបអុបទិក | អនុប្រធាន |
| ៣-លោក ហ៊ិន ប្រុស | អនុប្រធាននាយកដ្ឋានបញ្ជូនស៊ីញ៉ាល់និងបណ្តាញកាបអុបទិក | សមាជិក |
| ៤-លោក នុត មុនីរ័ត្ន | ប្រធានមណ្ឌល TMN ទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៥-លោក ម៉ាក្ស បុទុម | អនុប្រធានមណ្ឌលវិស្វកម្មទូរគមនាគមន៍កម្ពុជា | សមាជិក |
| ៦-លោក សៅ វណ្ណា | អនុប្រធានមជ្ឈមណ្ឌលបញ្ជូនស៊ីញ៉ាល់ទ.ក. | សមាជិក |

**គ-ក្រុមការងារហិរញ្ញកិច្ច:**

| | | |
|---|---|---|
| ១-លោក ណី សំកុល | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និង គណនេយ្យទ.ក. | ប្រធាន |
| ២-លោក ជា វណ្ណា | ប្រធានការិយាល័យហិរញ្ញកិច្ចទ.ក. | អនុប្រធាន |

**ប្រការ ២.-**

ក្រុមការងារខាងលើនេះមានភារកិច្ច:

- សហការការងារជាមួយក្រុមការងារ " GMS and CHINA-ASEAN Information Superhighway Working Group " ជាមួយក្រសួងព័ត៌មាន ឧស្សាហកម្ម នៃសាធារណៈរដ្ឋប្រជាមានិតចិន សំដៅពង្រីកប្រព័ន្ធបណ្តាញ GMS-IS ជាមួយបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ (GMS) និង អាស៊ាន (ASEAN)។
- សហការការងារជាមួយក្រុមការងារ ឬគណៈកម្មាធិការ ឬអង្គការដែលរៀបចំឡើងដោយភាគីជប៉ុន ពាក់ព័ន្ធការកសាងប្រព័ន្ធឆ្អឹងខ្នងក្នុងគម្រោង មេគង្គ-ជប៉ុន លើការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និង ASEAN SMART NETWORK ក្នុងគម្រោង មេគង្គ-ជប៉ុន និង អាស៊ាន (Mekong-Japan and ASEAN) ។
- សហការការងារជាមួយក្រុមការងារ ឬស្ថាប័នដទៃទៀតដែលមានការងារពាក់ព័ន្ធ។
- ត្រូវធ្វើរបាយការណ៍អំពីបច្ចុប្បន្នភាពសកម្មភាពការងារតាមកាលកំណត់ និងពេលចប់ភារកិច្ចត្រូវរាយការណ៍អំពីលទ្ធផលការងារជូនរដ្ឋមន្ត្រី ។

**ប្រការ ៣.-**

ក្រុមការងារ GMS និង Mekong Japan និងក្រុមការងារជំនាញនិមួយៗក្រោមឱវាទ ត្រូវអនុវត្តការងារតាមការដឹកនាំរបស់ប្រធាន និងចូលរួមប្រជុំតាមការអញ្ជើញ ឬចាត់តាំងរបស់ប្រធាន ឬប្រធានក្រុមការងារជំនាញនិមួយៗ ហើយអាចស្នើចាត់តាំងក្រុមការងារជំនាញផ្សេងទៀត តាមការងារចាំបាច់។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ទូរគមនាគមន៍-កម្ពុជា នាយកដ្ឋានពាក់ព័ន្ធ និងសមាសភាពដូចប្រការ១ ត្រូវទទួលបន្ទុកអនុវត្តការងារ តាមប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ប្រាក់-សុខុន

__កន្លែងទទួល:__

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

" ដើម្បីជូនជ្រាប "

-ដូចប្រការ៥

" ដើម្បីអនុវត្ត "

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ